
រឿង
កាកី

# រឿងនាងកាកី

(សរសេរដោយ ព្រះបាទ អង្គ ឌួង)

## អារម្ភកថា

សួស្តីបងប្អូនៗ អ្នកសិក្សា និងប្រិយ មិត្តអ្នកអានជាទីមេត្រី សៀវភៅរឿងកាកី ដែលប្អូនៗ និងប្រិយមិត្តកំពុង អានពេលនេះ គឺបានរៀបរាងឡើង តាមឯកសារកំណាព្យដែលជាព្រះរាជនិពន្ធរបស់ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះបរមកោដ្ឋ) និង តាមច្បាប់របស់ព្រះអង្គម្ចាស់ក្សត្រី មាលិកា ដោយពិតឥតមានកែប្រែ អត្ថន័យដើមឡើយ។

សៀវភៅនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង:ជួយសំរួលក្នុងការអានរបស់ប្អូនៗចង់ឲ្យប្អូនៗជំនាន់ក្រោយបាន យល់ពីអត្ថន័យនៃរឿងឲ្យបានច្បាស់ធ្វើជាមិត្តសំរាប់កែអផ្សុក ចំពោះប្អូនៗ និង ប្រិយមិត្តអ្នកអាន។

ទន្ទឹមនឹងនេះដែរ ខ្ញុំជឿជាក់ថាកំហុសឆ្គង ដោយអចេតនាខ្វះៗប្រាកដជាមាន ខ្ញុំនឹងរងចាំទទួលនូវរាល់ការទិតៀន កែលំអពិសំណាក់ ប្អូនៗ និងប្រិយមិត្តអ្នកអានដោយសេចក្តីរីករាយ។

## វគ្គទី ១

ក្នុងកាលកន្លងមក ពេលដែលព្រះមហាពោធិសត្វយោនយកកំណើតជាគ្រុឌមួយ ដែលមានឫទ្ធីបារមីខ្លាំងអស្ចារ្យស្ថិតនៅឯលើភ្នំព្រះសុមេរុ។

ក្នុងគ្រានោះដែរ ក៏មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមព្រហ្មទត្ត សោយរាជ្យសម្បត្តិនៅនគរពារាណសី។ ទ្រង់មានតិរៀង ម្នាក់ឈ្មោះថា"គន្ទ័ន" មានឫទ្ធីសិល្បសាស្រ្តដ៏ខ្លាំងពូកែ ឮល្បីពេញអស់កពផែនផងទាំងឡាយមិនតែប៉ុណ្ណោះគន្ទ័ន ចេះទាំងដេញពិណ ចេះទាំងច្រៀង ល្បិចល្បោយតែងកាព្យបានយ៉ាងស្ទាត់ជំនាញទៀតផង។ ព្រះបាទព្រហ្មទត្ត ទ្រង់សោយរាជសម្បត្តិល្បីល្បាញលើសលើលោកា ស្តេចមួយរយមួយប្រទេសតែងនាំសួយសារអាករមកថ្វាយមិនដែលដាច់ឡើយ។ ព្រះអង្គទ្រង់មានមហេសីមួយអង្គនាមកែវកាកី មានរូបឆោមលោមពណ៌យ៉ាងស្រស់សោភា ល្អគ្មានស្រីណាផ្ទឹមបានឡើយ។ កាកីបានកើតកាយ ចេញពីផ្កាកណិការដូច្នេះហើយទើបខ្លួនប្រាណនាងមានជាប់ក្លិនក្រអូប ឈ្ងុយឈ្ងប់ដោយ លំអងគន្ធា បើនរណាម្នាក់បានរួមរស់ស្នេហាជាមួយហើយលុះ៧រាត្រីទើបអស់ក្លិនក្រអូប ដោយលំអងគន្ធានោះ។ ព្រះអង្គព្រហ្មទត្តទ្រង់សព្វព្រះរាជហឫទ័យនឹងនាងកែវកាកីណាស់ ទ្រង់បានតែងតាំងកាកីជាអគ្គមហេសីលើសអស់ស្រីស្នំស្រីផ្កាទាំងពួង នៅកនុងវាំង។

ក្នុងកាលនោះ ស្តេចគ្រុឌដែលស្ថិតនៅឯចុងសិម្ពលីជាទីស្ថាន និងតេជះបារមី មានកំលាំងខ្លាំងក្លាអស្ចារ្យ អាចលោតផ្លោះឆ្លងមហាសាគរបានយ៉ាងងាយ មិនតែប៉ុណ្ណោះ គ្រុឌអាចប្រែកាយជាអ្វីក៏បានតាមចិត្តប្រាថ្នា។ គ្រុឌតែងហោះផ្លោះឆ្លងទៅកំសាន្ត បាស្កាជាមួយមហាក្សត្រសជាញឹកញយ ប៉ុន្តែមិនដែលចាញ់ឈ្នះទេ ជួនកាលគ្រុឌទៅសំរាកកំសាន្តជាមួយព្រះមហាក្សត្រទៀតផង លុះដល់វេលាទើបមកវិញ។

វេលាថ្ងៃមួយនោះ គ្រុឌនឹកចង់លេងបាស្កាជាមួយព្រះមហាក្សត្យ ក៏ហោះចេញចាក សិម្ពលីផ្លោះឆ្លងព្រៃភ្នំមហាសាគរ ហើយក៏បានមកដល់ គ្រុឌបានចូលទៅដើមជ្រៃធំមួយហើយ

ក៏បានសំដែងឫទ្ធិប្រែកាយជាកំលោះសង្ហាម្នាក់ បើស្រីណាម្នាក់បានឃើញហើយប្រាកដជាលង់ស្រលាញ់ជាក់ជាមិនខាន។ ប្រែកាយរួចស្រេចហើយគ្រុឌក៏បានចេញពីដើមជ្រៃដើរទៅរក ព្រះមហាក្សត្រព្រហ្មទត្ត ដែលទ្រង់គង់នៅក្នុងប្រាសាទ។ លុះទៅដល់ជិតហើយគ្រុឌកំលោះក៏ក្រាបសំពះអង្គស្តេចធ្វើហាក់ដូចជា ខ្លាចនឹងអំនាចទ្រង់ពេកក្រៃ។ ព្រះអង្គទ្រង់ទតឃើញមាណពដូច្នោះ ក៏ហៅឲ្យមកជិត រួចហើយទ្រង់ត្រាស់បញ្ជាឲ្យយកក្តាបាស្កាមកក្រសាលកំសាន្ត និងមាណព។

កាលនោះដែរនេងកែវកាកីដែលជាអគ្គមហេសី ព្រះអង្គ ដោយបាត់ស្វាមីយូរពេក ក៏សួរ ពួកភិលៀងទាំងអស់ថា តើស្វាមីយ៉ាងទៅណាទើបបាត់មិនឃើញមកយ៉ាងដូច្នេះ? ភិលៀងទាំងអស់បានឆ្លើយប្រាប់វិញថា ព្រះអង្គកំពុងក្រសាលបាស្កាជាមួយមាណពម្នាក់ដែលមានរូបរាងសង្ហាពន់ពេកក្រៃ។ គ្រាន់តែបានឮពាក្យភិលៀងទាំងអស់ប្រាប់ថាមានមាណពស្អាតសង្ហាមកលេង បាស្កាជាមួយព្រះអង្គនោះ កែវកាកីក៏កើតចិត្តបេតីចង់ឃើញមាណពនោះតែម្តង កែវកាកីក៏បានដើរទៅដល់ចុងរាជពេងហើយឈរអែបនៅទីនោះ កែវកាកីគយគន់សព្វប្រាណ របស់គ្រុឌហើយក៏ពេញចិត្តពេកក្រៃថែមទាំងចង់បានគ្រុឌជាស្វាមីទៀតផង។ គាប់ជួនពេលនោះមាណពរូបសង្ហាងើបភ័ក្រឡើងត្រង់ក៏ប្រទះឃើញនាងកែវកាកី ហើយក៏កើតចិត្តគុំគួចលួចបេតី ក្នុងចិត្តគិតថាៈ ស្រីនេះល្អអីល្អយ៉ាងនេះគ្មានទាស់ត្រង់ណាសោះឡើយ សូម្បីតែស្រី ក៏នៅមានទាស់ខ្វះដែរ តែនេះរកកន្លែងទាស់គ្មានទាល់តែសោះនេះបើយើងស្មានមិនខុសទេ នាងប្រហែលជាអគ្គមហេសីអង្គក្សត្រនេះហើយមើលទើបហ៊ានមកឈរដោយមិន ខ្លាចញញើតយ៉ាងនេះនោះ។ គ្រុឌបក្សាសំលឹងកាកីមិនដាក់ភ្នែក សំលឹងកាន់តែយូរកាន់តែមាន ចិត្តស្រលាញ់ខ្លាំងឡើងៗចំនែកឯកាកីដឹងថាគ្រុឌសំលឹងមកខ្លួនហើយ ក៏ញញឹមដៀងភ្នែកមើលចំហៀងផង ចំផង លុះខ្សែភ្នែកប៉ះចំគ្នាក៏ញញឹមដាក់ប៉ប្រែធ្វើឲ្យគ្រុឌញាប់ញ័រ អស់ហឫទ័យកើតសេចក្តីស្នេហាចំពោះនាងជាពន្ទពេក។ លុះឃើញថាគ្រុឌឈ្ងក់វង្វេងសំលឹងនាងមិនឈប់ហើយ កាកីក៏ធ្វើជាធ្លាក់ស្បៃដែលគ្របដណ្តប់លើរាងកាយធ្វើឲ្យសុដន់ទាំង គូរបស់នាងបានបង្ហួតបង្ហាញចំពោះភ្នែកគ្រុឌ

ដែលតាមសំលឹងគ្មានឈប់ នោះ។ គ្រុឌបក្សាឃើញហើយស្ទើតែស្ទុះទៅចាប់បីទៅតែម្តង ក្នុងពេលនោះទេ ប៉ុន្តែចិត្តមួយនៅនឹកគិតដល់កេរ្តិ៍ខ្មាស់ ដូច្នេះហើយទើបគ្រុឌខំសង្កត់ចិត្ត លេងបាស្កាជាមួយមហាក្សត្រ ដោយធ្វើយ៉ាងណាដើម្បីកុំឲ្យអង្គក្សត្រព្រហ្មទត្តចាប់អារម្មណ៍ រឿងហ្នឹងឡើយ។ ចំនែកអង្គក្សត្រព្រហ្មទត្តទ្រង់ក្រសាលបាស្កាយ៉ាងសប្បាយពុំបាន ចាប់អារម្មណ៍និងមហេសីដែលលបលួចប្រើខ្សែភ្នែកដាក់មាណពរូបសង្ហានៅ ចំពោះមុខព្រះអង្គឡើយ។ លុះព្រះសូរិយាទន់ទេរបន្ទាបខ្លួនចុះបន្តិច កែវកាគីក៏វិលត្រលប់ទៅរាជដំនាក់វិញ ដោយទុកឲ្យមាណពនៅខ្វល់ខ្វាយ ក្នុងចិត្តម្នាក់ឯងយ៉ាងក្រៃលែងក្នុងចិត្តគិតថាៈ

ត្រូវតែយកអគ្គមហេសីនេះទៅឲ្យបានក្នុងពេលនេះ។

គិតស្រេចមាណព ក៏ក្រាបបង្គំលាព្រះមហាក្សត្រចរចេញទៅយ៉ាងឆាប់ទៅដល់ដើមជ្រៃភ្នាម មាណពក៏សែកមន្តវិជ្ជាប្រែក្រលាទៅជាគ្រុឌយ៉ាងធំសំបើម ហើយហោះឡើងទៅលើមេឃបង្កខ្យល់ព្យុះយ៉ាងខ្លាំងងងិតអស់កពផែនពសុធា។

ព្រះអង្គព្រហ្មទត្តទ្រង់យល់ហេតុការណ៍ ចំលែកពេកអស្ចារ្យទ្រង់យាងទៅគង់មុខនាម៉ឺនសព្វមុខមន្ត្រីនិង សេនាបតីយទាំងឡាយ ដែលកំពុងផ្អើលនឹងហេតុការណ៍ដ៏ចំលែកនេះ។ ចំនែកគ្រុឌហោះផ្ងោះផ្ងោងវិលងអស់កពផែនដី រួចហើយក៏ចុះចូលទៅដល់កន្ទែងរបស់កែវកាគី ឃើញហើយគ្រុឌក៏បាននិយាយលួងលោមថាៈ

ហៃប្អូនមាសស្ងួនមាសបងអើយ ប្អូនដឹងទេថាបងនេះហើយជាមាណពពីថ្ងៃនោះ ចាប់តាំងពីពេលដែលបានឃើញប្អូនមក ចិត្តបងមិនមានស្ងប់ឡើយ ចង់បានប្អូនជាគូគាប់ភ្ជាប់និស្ស័យពីពេលនេះតទ្បូវនេះទៅ ប្អូនអើយបងខំប្រឹងហិចហោះផ្ងោះស្កាត់មករកប្អូនហេតុអ្វីក៏ ប្អូនធ្វើមិនដឹងផ្ទុំលក់ធ្វើព្រងើយយ៉ាងនេះ។ បងនេះនឹងនាំប្អូនទៅទីស្ថានរបស់បងដែលជាស្ថានសុខស្ងួត មានសម្បត្តិមហាសាល គ្មានទ្រព្យសម្បត្តិមនុស្សណានឹងប្រៀបបានឡើយ បងនឹងនាំប្អូនហោះផ្ងោះដែនមហាសាគរ ដែនគិរីបុព្វតាទៅមើលម្រឹគីម្រឹគាបក្សាកប្បីហិច ហើរច្រៀងបំពេរនៅ ទីស្ថានព្រះឥស្សូ។ លួងលោមរួចស្រេចហើយគ្រុឌក៏លើកត្រកងអង្គ

ប្រាណកែវកាកីថៃថើបដោយ ក្ដីស្រលាញ់ពន់ពេកពុំចេះឆ្អែតឆ្អន់ឡើយ។ ចំនែកកាកីនាង បានស្ដាប់ឮអស់ស័ព្ទសំដីដែលគ្រុឌបាននិយាយទាំងអស់ តែនាងមិនហ៊ានឆ្លើយតបទេ ព្រោះថាបើនឹងឆ្លើយថាព្រមនោះដូចជាអៀនមាត់ទើបនាងសំងំធ្វើជាកំពុង លង់លក់ដោយ មិនដឹងខ្លួន។

## វគ្គទី ២

ដោយឃើញឱកាសល្អក៏ហោះនាំកែវកាកីទៅដល់ទីស្ថានរបស់ខ្លួន ដោយគ្មាននរណា ម្នាក់បានដឹងដានសោះឡើយ។

ដល់ហើយគ្រុឌបានដាក់កែវកាកីលើទីទែន សយនា ហើយក៏ប្រែប្រាណជាទេវបុត្រ មួយរូបដ៏ស្រស់សង្ហា ចូលទៅបបោសអង្អែលថៃថើបកាកីដោយក្ដីស្រលាញ់ពេកកន្លង។ ចំនែកកាកីប្រើកិរិយាធ្វើជារុញច្រាន រូបអង្គទេវបុត្ររួចនិយាយថាៈ

ឱព្រះអង្គអើយ ខ្ញុំម្ចាស់នេះមានស្វាមីរួចទៅហើយ មិនគួរឡើយព្រះអង្គមកស្នេហា ចំពោះខ្ញុំមចាស់ដូចនេះទៀតទេម្យ៉ាងទៀត ព្រះអង្គមិនគួរឡើយមានព្រះទ័យមិនស្មោះត្រង់ នឹងក្សត្រាទៅលបលួចយក ខ្ញុំម្ចាស់ដោយមិនគិតអាណិតដល់ព្រះទ័យព្រះអង្គតិចតួច ឡើយ ហើយនេះបើខ្ញុំមចាស់ព្រមស្រលាញ់ ព្រះអង្គខ្លាច ក្រែងថ្ងៃក្រោយទៅ ព្រះអង្គ ណាយចិត្តឈប់ស្រលាញ់ខ្ញុំម្ចាស់ទៅយកស្រីសួរមកវិញនោះ ខ្ញុំមចាស់នឹងទៅជាយ៉ាងណា អ្នកផងនឹងដៀលថាជាស្រីស្រើបមានស្វាមីហើយឆ្លៀតទៅយកប្ដីជាគ្រុឌ ទៀត ចំនែក ព្រះអង្គក៏មានឈ្មោះថាជាអ្នកលួចភរិយាគេមកដែរ។

គ្រុឌស្ដាប់ឮសំដីកាកីនិយាយត្អូញត្អែរសព្វគ្រប់ហើយ ក៏ឆ្លើយវិញថាៈ

បងនេះដឹងហើយថាប្អូនមានស្វាមីរួច ចំណែកព្រះអង្គទ្រង់ក៏ស្រលាញ់ទុកព្រះទ័យចុះពោះ បងខ្លាំងណាស់ដែរ តែបងមិនខ្លាចទ្រង់ឡើយបើសិនជាទ្រង់សណ្ដាប់រឿងនេះនោះ។ ប្អូន ដឹងទេកាលពីព្រឹកមិញនេះ បើតាមចិត្តដែលស្រលាញ់ប្អូននោះ បងស្ទើរតែស្ទុះទៅកន្ត្រាក់

ចាប់បីប្អូនហោះមកតែម្តងទៅហើយ តែនេះបងការកេរ្តិ៍ទាំងប្អូនទាំងបង ដូច្នេះហើយទើបបងទ្រាំដល់យប់ទើបបានយកប្អូនមកទីនេះ ប្អូនអើយប្អូនគិតក្រែងគេនិន្ទាដៀលបងថាលួចភរិយាគេ តែប្អូនកុំភ័យថ្វីព្រោះកាលដែលបងយកប្អូនមកនេះ មិនមាននរណាមួយស្គាល់ដឹងថាបងនេះជាអ្នកនាំប្អូនមកទីនេះឡើយ។

កែវកាកីស្តាប់គ្រុឌហើយសេនពេញចិត្តពេកក្រៃក្នុងចិត្តជ្រួលច្របល់ស្មានមិនត្រូវ តែសង្កត់ចិត្តធ្វើជានិយាយថាៈ

នេះព្រះអង្គពោលពាក្យបែបនេះនាំឲ្យ ខ្ញុំម្ចាស់រឹងរឹតតែសង្ស័យថា ស្រីសួរគេគោកម្តេចក៏ព្រះអង្គមិន សព្វព្រះទ័យ បែជាមកសព្វព្រះទ័យអ្វីលើរូបខ្ញុំម្ចាស់ដែលជាស្រីនៅផែនដីនោះ ឬមួយក៏ព្រះអង្គពោលថា ស្រលាញ់តែព្រះឱស្ឋព្រះអង្គទេ បើដូច្នោះមែនខ្ញុំម្ចាស់នឹងសោកសង្រេងអស់មួយជីវិតហើយ។

គ្រុឌបានស្តាប់កាកីនិយាយរួចហើយក៏ឆ្លើយលួងលោមវិញថាៈ

ឱកែវកាកីប្អូនសំលាញ់អើយ ពិតមែនតែស្រីសួគ៌សែនស្រស់ល្អ ស្អាតមានគគោកក៏ពិតមែន តែបងនេះមិនត្រូវហរទ័យសោះ ប្អូនកុំភ័យថាបងនេះនឹងដោះដៃចោលប្អូននោះ ចូរប្អូនជឿបងចុះថា ពាក្យដែលបងនិយាយហើយជាពាក្យពិត។

ស្តេចគ្រុឌមាត់ចេះតែនិយាយ ដៃចេះតែបបោសអង្អែលកែវកាកី ឲ្យលង់ក្នុងអារម្មណ៍រកស្មានមិនត្រូវតែមាត់ចេះតែនិយាយថាអាណិត ខ្លួនដែលត្រូវមកបង្ខំប្រតិព័ទ្ធ ដោយមិនអាចជួយ ឬតវ៉ាបានព្រោះខ្លួនជាស្រីហើយមានតែមួយអង្គឯង។

ទោះជាកែវកាកីខំនិយាយយ៉ាងណាក៏គ្រុឌ មិនបានគិតឬស្តាប់អ្វីទាំងអស់ គេគិតតែបីក្រសោបឱបប្រាណកែវកាកីហើយក៏ស្រង់ក្លិនខ្លួនកែវកាកី ដែលជាក្លិនពិដោរយ៉ាងពិសេសលើសអស់ស្រីនានាលើភពផែនដីហើយក្លិនយ៉ាង ពិសេសដែលគ្រុឌបានទទួលហើយនោះ ធ្វើឲ្យគ្រុឌភ្លេចអស់ព្រៃព្រឹក្សា ភ្លេចអស់អាហារដែលធ្លាប់តែបរិភោគក្តាជា

រឿងរាល់ថ្ងៃៗ ចំនែកកាកីពេលនេះនាងក៏ភ្លេចអស់នូវអ្វីៗ ដែលធ្លាប់មានពីមុនមកដែរ ដូចជាល្បែងកំសាន្តផ្សេងៗ ទាំងឧទ្យានដែលធ្លាប់លេងកំសាន្តជាពិសេសនាងភ្លេចទាំងព្រះមហាក្សត្រ ព្រហ្មទត្តដែលជាស្វាមីនាងទៀតផង។

យើងឈប់ស្នេះរឿងកែវកាកីនិងស្តេច គ្រុឌតែត្រឹមនេះសិន សូមបែមកមើលឯព្រះរាជវាំងវិញម្តង ក្រោយពេលដែលមេឃងងិតព្យុះភ្លៀងត្រូវបានស្ងប់ស្ងាត់ហើយនោះព្រះរាជាព្រហ្មទត្តយាងចូលក្រឡាបន្ទំដើម្បីរកព្រះមហេសីកែវកាកី ស្រាប់តែស្ងាត់ឈឹងទ្រង់ស្ទុតអស់អង្គព្រះកាយ ទ្រង់ដណ្តឹងសួរអស់ស្រីស្នំកិលៀងទាំងឡាយ គ្មាននរណាម្នាក់បានដឹងឡើយៗ ព្រះអង្គទ្រង់ចាត់ឲ្យរត់រកគ្រប់ទីកន្លែងដែនមណ្ឌលនៅតែមិនបានជួប ទីបំផុតព្រះអង្គព្រហ្មទត្តទ្រង់ព្រះកន្សែងនឹកស្តាយកែវកាកីជា ពន់ពេកទ្រង់ព្រះចិន្តាថាៈ

ឱមាសមិត្តរបស់បងអើយពេលនេះតើឲ្យបង ទៅរកប្អូននៅឯណា? ប្អូនអើយបងនេះសែនស្តាយប្អូនពេកកន្ទង់ព្រោះថាប្អូនជាស្រី ដែលដឹងអស់ការរាក់ជ្រៅដឹងទាបដឹងខ្ពស់សមជាឯកក្សត្រីស្រីកល្យាណ មែនៗ បងស្តាយប្អូនមានប្រាជ្ញា ចេះចាត់ចែងចរចារពុំចេះធ្វល់ដល់អ្វីឡើយៗ ប្អូនចេះដឹងសុខទុក្ខដល់ស្រីស្នំទាំងឡាយ ប្អូនអើយបើគិតដល់ក្និនខ្លួនទួនស្រីដែលធ្លាប់ផ្ទុំផ្ទឹមខ្នើយនិង បងនោះបងគិតថានឹងគ្មានស្រី ណានឹងប្រដូចបានទេ បងធ្លាប់យល់ក័ក្រប្អូនគង់ក្រសាលជិតបង ធ្លាប់ស្រង់គង្គារ និងរាំលេងកំសាន្ត នាំឲ្យទុក្ខសោកទាំងប៉ុន្មាននិរាសចេញបានហើយយល់តែសេចក្តីសុខ ស្កប់ស្កល់ពេញទាំអកាយ ប៉ុន្តែប្អូនអើយពេលនេះតើប្អូនព្រាត់ទៅឯណា? តើបានសុខឬ ក៏ជាទុក្ខ? ប្អូនអើយបើពេលនេះបងដឹងថាប្អូននៅស្ថានណានោះ បងនឹងតាមទៅយកប្អូនមកវិញជាក់ជាមិនខាន តែពេលនេះព្រលឹងមាសបងអើយ បងបានតែគិត និងរង់ចាំប្អូនតែប៉ុណ្ណោះ។

ស្តេចព្រហ្មទត្តទ្រង់សោកសង្រេងនឹក ជាយាគ្រប់ទិវារាត្រី ទ្រង់ភ្លេចទាំងស្រង់គង្គារ ភ្លេចអស់ទាំងល្បែងដែលទ្រង់ធ្លាប់ក្រសាលកំសាន្ត ភ្លេចអស់ស្រីស្នំនិម្មលទាំងឡាយ ពេលសោយក្រយាស្ងោយទ្រង់សោយទាំងទុកសោកគ្រាមក្រំពេកកន្ទង់។ ទីបំផុតព្រះអង្គទ្រង់ក៏

ត្រាស់បញ្ជាឲ្យហៅគន្ធ័ន មកចូលគាល់ព្រះអង្គហើយទ្រង់បានប្រាប់រឿងដែលជាយាបាន បាត់ពី ប្រាសាទ។ គន្ធ័នបានស្តាប់ហើយក៏ក្រាបសម្តេចព្រហ្មទត្តហើយទូលថាៈ

សូមទ្រង់ព្រះមេត្តាប្រោស កាលដែលព្រះអង្គទ្រង់ក្រសាលបាស្កានិងថៅមាណពនោះ ទូលបង្គំជាខ្ញុំបានឃើញព្រះមហេសីទ្រង់យាងផ្ទោះទៅទ្វារហើយមើលទៅថៅ មាណព ចំនែកថៅមាណពក៏បានមើលទៅ ព្រះមហេសីវិញដែរ ហើយក៏បានញញឹមដាក់គ្នាទៀតផង។ ទូលបង្គំជាខ្ញុំឃើញហើយមានសេចក្តីក្រោធ យ៉ាងខ្លាំងជំនួសព្រះអង្គ ទូលបង្គំស្ទើរតែស្ទុះទៅស៊ីសាចើទាំងរស់ទេ ប៉ុន្តែទូលបង្គំខំទប់កំហឹងហើយសញ្ជឹងគិតថា បើសិនណាថៅមាណពជាមនុស្សធម្មតានៅស្រុកអាយហេតុម្តេចក៏ឃើញហើយមិន ថ្វាយ បង្គំយ៉ាងនេះ ម្យ៉ាងទៀតបើអ្នកមកពីឆ្ងាយវិញនោះហេតុម្តេចក៏ទៅមកបានឆាប់យ៉ាងនេះ? ទូលបង្គំគិតមើលទៅឃើញថាប្លែកណាស់ ឬមួយក៏ថៅមាណពជាក្រុងគ្រុឌក្លែងរូបកាយបំភ័នភ្នែកដើម្បីលេង បាស្កា និងព្រះអង្គ ហើយលបលួចយកអគ្គទេពីទៅសោយសុខនៅសិម្ពលី ហើយមើលទៅទូលបង្គំយល់ដូច្នេះ ប៉ុន្តែយ៉ាងណានោះសូមទានល្អងធូលីព្រះបាទរង់ចាំ៧ថ្ងៃសិនទូលបង្គំគិតថាគេប្រាកដជានឹងមកជាមិនខានពេលនោះយើងនឹងតាមដានឲ្យ បានដឹងការពិត ហើយបើបានដឹងប្រាកដហើយយើងនឹងប្រើកលយ៉ាងណាដើម្បីឲ្យគេជូនព្រះមហេសីត្រឡប់មកវិញ។

អង្គក្សត្រព្រហ្មទត្តទ្រង់ស្តាប់គន្ធ័នហើយ ហាក់បានធូស្បើយក្នុងអារម្មណ៍ខ្លះទើបមានព្រះបន្ទូលថាៈ

ហៃគន្ធ័នបងសំលាញ់អើយ បើពិតដូច្នោះមែនអង្គអញសែនត្រេកអរក្រៃហើយដូច្នេះចូរបងរៀបចំ ប្រុងប្រៀបផងចុះហើយកាលដែលធ្វើដំនើរក្នុងផ្លូវឆ្ងាយនោះ ចូរបងប្រយ័ត្នប្រយែងខ្លួនប្រាណផង ហើយយ៉ាងណាៗនោះសូមបងឆាប់ត្រឡប់មកវិញ។

គន្ធ័នស្តាប់ហើយក៏ក្រាបបង្គំលា ព្រះមហាក្សត្រត្រលប់ទៅទីស្ថានរបស់ខ្លួនវិញ ចំណែកអង្គក្សត្រទ្រង់ក៏យាងចូលក្រឡាបន្ទំដែរតែទ្រង់ចេះតែមានការ សោកសៅនឹករលឹកកែវកាកីជានិច្ច។

## វគ្គទី ៣

យើងឈប់ស្ទេះរឿងស្តេចសោយសោកត្រឹមនេះ សិន យើងបែមកមើលស្តេចគ្រុឌនិង កែវកាកីវិញ ម្តង នៅពេលដែលគ្រុឌនិង កាកីបានតើនពីផ្ទំមកនោះ ស្តេចគ្រុឌបានលោម កាកីថា:

ឱប្អូនស្ងួនមាសមែស្រីសោភា បងនឹងនាំប្អូនទៅកំសាន្តដល់ជ្រុងជ្រោយព្រៃជ្រៅ រួចហើយ និងហួសទៅដល់ស្រះដលស័យទៀតផង។

និយាយរួច ស្តេចបក្សាក៏លើកបីត្រកងកាកីហើយហោះផ្លោះគិរីសុមេរុជាទីកំសាន្ត ទ័យាគ្រុឌរៀបរាប់ប្រាប់កាកីថា:

- ប្អូនអើយប្អូនមើលបុព្វតាសុមេរុវ ង្គ្លលនេះ គួរស្ញប់ស្ញែងណាស់គឺថាកំពូលដ៏ខ្ពស់របស់វា មានពន្លឺ ចិញ្ចែងចិញ្ចាចសឹងជាមណីរង្សី និងប្រៀបបានដូចជាសែងសូរិយាសន្ធោសន្ធៅ ក្រហមប្រាលផ្ទិនផ្ទៅ ដូចជាត្បូង ទទឹមដែលចាំងឆ្លុះនឹងថ្មនិល ប្អូន អើយសឹងមានពន្លឺភ្លឺផ្ទេក ទាំងអស់ ចំណែកព្រៃដ៏ខៀវស្រងាត់នេះ វិញ ប្អូន មើលត្រង់កន្លែងនោះជាទីកន្លែងទឹកធ្លាក់ ដ៏ខ្ពស់ដែលមានទឹក ហូរស្រោចស្រពទៅសមុទ្រ ហើយចំនែកនៅសមុទ្រវិញ ប្អូនមើលចុះ មានមច្ឆា តូចធំ ហែបហែលគាំងគូប្រដេញគ្នាយ៉ាងសប្បាយ ខ្លះទៀតលោតទៅពាំ ចាប់ចំណី ទន្ទាំទន្ទេងបង្កឲ្យមានរលកទឹកខ្វះខ្វាយមើលទៅគួរឲ្យសប្បាតណាស់។

បន្ទាប់ពីបានរៀបរាប់សុមេរុវង្គ្ល ល និងសមុទ្រមកស្តេចបក្សាក៏ហោះហើរនាំកែវកាកី ទៅមើលដល់ព្រះ ហេម ពាន្ត មើលគិរីបុព្វតា សត្វបក្សាបក្សីម្រឹគីម្រឹគាតូចធំ ដេញ ប្រឡែង

គ្នាពេញព្រៃព្រឹក្សាមើលទៅគួរអោយ សប្បាយរីករាយណាស់។ លុះមើល ចប់សព្វគ្រប់ ហើយគ្រុឌក៏នាំកែវកាគីត្រឡប់ទៅក្រុងសិម្ពលីវិញ។

ផ្ទេចបើកៗដល់គំរប់៧ថ្ងៃស្តេចគ្រុឌគិតថាៈ

- ឱកាសអង្គអញលបលួចកែវកាគីមកសិម្ពលីនេះដលើគំរប់៧ថ្ងៃហើយ គឺដល់ពេល ដែល អញត្រូវទៅលេង បាស្កាជាមួយស្តេចព្រហ្មទត្តទៀតហើយ នេះបើអញមិន ទៅទេនោះគេ នឹងសង្ស័យមកលើរូបអញថាលួច ពង្រត់នាងកែវកាគីជាក់ ជាមិនខាន។

គិតស្រេចហើយទើបគ្រុឌសំរេចចិត្តប្រាប់កែវកាគីដោយលួងលោមថាៈ

- ហៃកែវកាគីថ្លើមរបស់បងអើយ ពេលនេះគឺ ដល់ពេលកំនត់៧ថ្ងៃដែលបងត្រូវទៅលេង បាស្កាហើយ ចូរប្អូន នៅទីនេះចុះ ណ៎ា បងសូមលាប្អូនទៅតែមួយថ្ងៃប៉ុណ្ណោះ លុះរសៀល ព្រះសូរិយាបងនឹង ត្រលប់មកជួបប្អូន វិញជាក់ជាមិនខាន។

កាគីស្តាប់គ្រុឌនិយាយរួចហើយ ក៏បង្គំទូលវិញថាៈ

- បពិតព្រះអង្គដ៏មានគុណអើយ សូម ព្រះអង្គគន់គិតប្រណីដល់រូបកាគីជាស្រី បើទុកនៅ កន្ទែងតែអង់ ឯង ដូច្នេះប្អូនពិតជាខ្លាចណាស់ រាល់ថ្ងៃកាគីនិត្យនៅគ្រាន់បាន ព្រះអង្គជាទី ពំនាក់ ឥឡូវបើព្រះអង្គយាងទៅ ប្អូនពិតជាខ្លាច ណាស់ ខ្លាចខ្មោចព្រៃស្ថិតនៅទីស្ថាននេះ ឬ មួយក៏មានយក្សសាមាន្យមក ប៉ងព្យាបាទលើរូប ប្អូននោះប្អូនពិតជាមិនអាចតបូទ្ធិនិងគេ បានទេនេះ ម្យ៉ាង ម្យ៉ាងទៀតប្អូននេះធ្លាប់មានប្រុសមួយហើយលែងលះបង់មករួមរស់ និង ប្រុសដទៃ ឃើញថាវាពុំប្រពៃរួចទៅហើយ នេះបើថែមប្រុសថ្មីមួយទៀត នោះ វាប្រាកដ ជា ខុសនិងច្បាប់ពេកណាស់ណ៎ាដូច្នេះសូមព្រះអង្គកុំយាង ទៅចោលខ្ញុំម្ចាស់ថ្មី។

គ្រុឌបក្សាស្តាប់ពុ្ធកែវកាគីនិយាយអង្វរដូច្នេះ ហាក់មានចិត្តទោរទន់អាណិតក៏លួងលោម វិញថាៈ

ហៃកែវកាកីថ្ងៃមថ្លៃមាសបងអើយ ពេលនេះណា បើបងមិនទៅទេ ម្ដេះសមគេនឹងគិតថា បងនេះបានលប លួចយកប្អូនមកមិន ខាន ប្អូនអើយចូរប្អូនកុំសោកាថ្វី ព្រោះថាបងទៅមិនយូរឡើយ ត្រឹម សូរិយាទន់ទេបងនឹងវិលវែរកប្អូនជាក់ជាមិនខាន មួយទៀតបងនឹងសែកមន្ត ចងទ្វារប្រាសាទហើយទោះបីជាខ្មោច ព្រាយ បីសាចឯណាក៏ដោយមិនអាចស្រាយ បានឡើយ។

លួងលោមរួចហើយ គ្រុឌបក្សាបានត្រកងកែវ កាកីយកដាក់លើក្រឡាបន្ទំ រួចក៏ចេញមកសែកមន្តចងទ្វារ ប្រាសាទហើយ ក៏ ហោះផ្ទោះរំលងជលសារគិរីបុព្វតារួចហើយក៏មកដល់គោលដៅដើមជ្រៃដូច បំណង គ្រុឌក៏បានប្រែប្រាណជាមាណពកាលណាក៏ប្រញាប់យាត្រាទៅរកប្រាសាទ ដែលអង្គព្រហ្មទត្តគង់នៅ។

ព្រះមហាក្សត្រទ្រង់ទតឃើញមកដល់ដូច្នោះ មានសេចក្ដីក្រោធយ៉ាងខ្លាំង ប៉ុន្តែទ្រង់ខំរំងាប់សេចក្ដីក្រោធ ធ្វើ ជាមិនដឹង ទ្រង់ត្រាស់បញ្ជាឲ្យរៀបក្ដារបាស្កាមាណពគ្រុឌហាក់រអៀសខ្លួនដែរ តែធ្វើពើជាមិនដឹងអ្វីទាំង អស់អង្គុយលេង ជម្មតា។ លុះដល់សូរិយាទន់ទេរជ្រេបន្តិច មាណពក៏ក្រាបសមពះលាស្ដេច ត្រលប់ទៅទី ស្ថានរបស់ខ្លួនវិញ មាណពធ្វើដំនើរសំដៅទៅដើមជ្រៃដោយ មិនដឹងខ្លួនថា មានគន្ធ័នដើរតាមពីក្រោយទេ។

ដល់ដើមជ្រៃហើយមាណពក៏ប្រែប្រាណជា គ្រុឌភ្លៀម ចំណែកគន្ធ័នវិញ ក៏ប្រែប្រាណជាស្រមើលដ៏តូចមួយទុំ លើរោមរបស់គ្រុឌ។ ដោយក្នុងចិត្តនឹកទៅដល់កាកី ហើយប្រញាប់ត្រលប់ ទៅវិញនោះ គ្រុឌមិនបានចាប់ អារម្មណ៍ដឹងថាមានអ្វីតោងខ្លួននោះឡើយ គេ បានហោះផ្ទោះជលសារសំដៅសិម្ពលីភ្លាម ដល់ហើយក៏ស្រាយមន្តបើកទ្វារប្រាសាទហើយចូលទៅរកកែវកាកីដោយក្ដីសប្បាយរីករាយក្នុងចិត្ត ឥតឧបមា ទាំងពីរកាយាសេពសុខសោតនិទ្រាឥតមានអំពល់ខ្វល់អ្វីឡើយ។

ព្រឹកព្រាងភ្លឺស្វាងព្រះសូរិយាចាំង ធ្ទុះរស្មីភ្លឺត្រចះឯមណ្ឌលសិម្ពលីក្រុងគ្រុឌតើនពីក្រលាបន្ទំ ហើយក៏សំណេះសំណាលនិងកែវកាកីមហេសីសំណពព្រមទាំងលានាងឧត្តម

ដើម្បីចេញទៅរកចំណីអាហារនៅឯព្រៃព្រឹកឡាលុះលារួចហើយក៏ចេញ ចាកមកក្រៅហើយសែកមន្តចង់ទ្វារប្រាសាទហើយក៏ហោះផ្លោះផ្លោងចេញទៅ បាត់។

ក្រោយពេលដែលគ្រុឌចេញទៅផុតបន្តិចគន្ធ័នក៏ប្រែប្រាណមកវិញ កាកីបានឃើញគន្ធ័នដូច្នោះក៏គិតថាៈ

- នេះមុខជាព្រះមហាក្សត្រត្រាណត្រើយប្រើឲ្យមករកអញហើយ គួរអញប្រើកលដើម្បីឲ្យគន្ធ័នយល់ថាអញនេះព្រួយចិត្ត។

គិតរួចស្រេចហើយកាកីក៏និយាយទៅកាន់គន្ធ័នថាៈ

- ឱថ្ងៃនេះជាភព្វល្អរបស់ខ្ញុំពេក ក្តាត់ ដែលបានជួបបងគន្ធ័ន ធ្វើឲ្យប្អូនបានធូស្បើយក្នុងចិត្តខ្វះ បងអើយប្អូនសព្វថ្ងៃកើតទុក្ខអ្វីម្ល េះទេ គិតថានឹងមិនបាន ត្រលប់ទៅវិញទេ តែពេលប្អូនបានធូរចិត្តហើយ ប្អូនចង់ដឹងថាបងមកដោយ វិធីណាទៅ? ព្រះអង្គប្រើឲ្យបងមក ឬមួយក៏បងដឹងហើយមកដោយចិត្តឯង?

គន្ធ័នស្តាប់កាកីហើយក៏ឆ្លើយទៅវិញថាៈ

- ខ្ញុំបាទមកទីនេះដោយចិត្តឯង ទេ មិនមាននរណាម្នាក់ដឹងឡើយ។ ខ្ញុំបាននិម្មិតកាយអោយតូចហើយជ្រែក តោងរោមគ្រុឌមកទេចំនែកព្រះអង្គទ្រង់ពុំបានព្រួយព្រះទ័យគិតដល់អ្នកឡើយ តែចំពោះខ្ញុំវិញកាល ដែលខ្ញុំខំប្រឹងស្វះស្វែងមកនេះគឺខ្ញុំ នឹកអាណិតដល់អ្នកទេឥលូវព្រេងវាសនាគឺបាននាំខ្ញុំអោយមកជួបអ្នក ពិតមែន។

កាកីឮពាក្យគន្ធ័ននិយាយពាក្យបញ្ចូល ចិត្តប៉ងលើរូបខ្លួនដូច្នោះ ក្នុងចិត្តគិតអរដែរ តែធ្វើជាស្មោះ ចំពោះព្រះមហាក្សត្រទើបឆ្លើយវិញថាៈ

- នេះពិតជាបុណ្យព្រេងសំណាងមែនហើយ ដែល បាននាំបងអោយមកដល់ទីនេះ ខ្ញុំគិតថា វាជាផ្លូវដ៏ល្អដែលបងនាំ ដំណឹងទៅទូលព្រះអង្គ ទ្រង់ប្រាកដជាសប្បាយព្រះទ័យ ហើយនិង សងបងយ៉ាង ពេញចិត្តជាក់ជាមិនខាន។

- ខំស្កាត់ពីនាយដល់អាយសង្វាតស្វែងរក ស្មើស្លាប់ខ្លួន បានមកដល់ហើយគ្មានបានទទួល គុណអ្វី សូម្បីតែ បន្តិច បែជាអោយព្រះមហាក្សត្រសងគុណជំនួសឯនាយឯណោះ ទៅវិញ ទ្រង់ប្រាកដជាមិនបានដឹងពីការដែលខំស្វះស្វែងនោះទេ គួរណាស់តែ អ្នកនៅឯនេះដឹង គុណខ្វះទើបគួរសម (គន្ធ័នធ្វើឆ្វើយបែបអន់ចិត្ត)

កាកីស្តាប់ហើយធ្វើជាសើចហើយនិយាយថា:

- តើខ្ញុំមានអ្វីថ្លៃថ្លាទៅដែលធ្វើអោយបងគន្ធ័នអរនោះ?

- មានគឺពិតជាមាន តែអ្នកពុំនឹកដល់សោះ

- បងថាប្អូនមានអ្វីនោះប្អូនមិនដឹងទេ តែប្អូនមានតែខ្លួន ប៉ុណ្ណោះ នឹងធ្វើជាខ្ញុំបំរើគ្រែងមិន ទទួល ហេតុនេះ ហើយទើបប្អូនថា មិនមាននោះ។

គន្ធ័នស្តាប់កាកីហើយក៏ញញឹមសងវិញហើយនិយាយថា:

ខ្ញុំនេះសង្វាតមកពីនាយដល់អាយ គ្មានគិតប្រាថ្នាអ្វីគិតតែម្យ៉ាងតែប៉ុណ្ណោះ ថាបើ បាននោះអរលើសអ្វីៗទាំងអស់។

- តើអ្វីទៅដែលអ្នកប្រាថ្នានោះ? (កាកីធ្វើពើសួរគន្ធ័ន)

## <u>វគ្គទី ៤</u>

-គឺរូបអ្នកនឹងហើយដែលខ្ញុំប្រាថ្នា បើអ្នកព្រមស្រលាញ់ខ្ញុំនោះ ខ្ញុំពិតជាអរលើសអ្វីទាំងអស់ មែន។

កាកីស្តាប់គន្ធ័នហើយ នាងក៏មានចិត្តត្រេកអរដែរតែធ្វើជាស្មោះចំពោះស្តេចព្រហ្មទត្ត ក៏ឆ្លើយទៅវិញថាៈ

នោះមិនបានទេណ៎ាបង ប្អូននេះខ្លាចថាបងនឹងបង់ទ្រព្យ នឹងរកដោះខ្លួនមិនរួចណាបង។

គន្ធ័នឮកាកីនិយាយដូច្នោះ ក្នុងចិត្ត កើតក្តីប្រតិព័ទ្ធយ៉ាងខ្លាំងក៏ខិតចូលជិតនៃបនិត្យកាយ លូកដៃអោបកាកូនៃបនិត្យដោយក្តីស្រលាញ់ពេញចិត្តយ៉ាងខ្លាំង។ ចំនែកកាកីក៏ពេញចិត្តចំពោះគន្ធ័នដែរ ប៉ុន្តែកាកេរ្តិ៍ជាស្រីនាង ធ្វើជានិយាយថាៈ

អញស្មាញជាស្មោះ ថាទៅប៉ុណ្ណោះស្រាប់តែវិលវេះ ប្រលោមប្រលែង អញឯងអញនេះ ហ៊ាមហួសម្តេចម្ដេះ អញពុំដែលយល់។

មាត់ចេះតែប្រកែកដោយកលមាយា ចំនែក ខ្លួនប្រាណបណ្តោយអោយគន្ធ័នកៀកកើយតាមអំពើចិត្ត។ គន្ធ័នយល់ថានាង មិនប្រកែកអ្វីទេ នោះក៏រួមរស់យ៉ាងសុខក្សេមក្សាន្តនឹងគ្នា បំភ្លេចចោលនូវអ្វីទាំងអស់ សូម្បីតែសង្សារថ្មោងថ្មីរបស់កាកីក៏ត្រូវ ភ្លេចដែរ។

លុះព្រះសូរិយាបន្ទាបខ្លួនចុះ បន្តិចម្តងៗបាំងបាត់ និងគិរីទើបគន្ធ័នប្រែកាយជាសភាពដើមវិញ។ ដើម្បីកុំអោយគ្រុឌ សង្ស័យ។ ចំនែកគ្រុឌបេះបានផ្លែផល្លាគ្រប់មុខហើយ ចរចូលមណ្ឌលវិញដោយ ពុំបានដឹងថា គន្ធ័នមកលួចរួមរស់នឹងកែវកាកីទេ។ ធ្វេចបើកៗរយៈពេល៦ថ្ងៃបានកន្លងផុតទៅយ៉ាងឆាប់រហ័សថ្ងៃទី៧ក៏បានចូលមក ដល់គ្រុឌបានរៀបចំប្រាណហើយផ្តែផ្តាំលាកែវកាកីសង្សាថ្មោងថ្មី បណ្តូលចិត្តដើម្បីទៅលេងបាស្កាជាមួយនឹងព្រះអង្គព្រហ្មទត្តចំនែកគ ន្ធ័នដឹងការដូច្នោះក៏មកក្បែរហើយតោងពេមគ្រុឌបានយ៉ាងងាយដោយគ្រុឌមិនចាប់អារម្មណ៍សូម្បីតែបន្តិចឡើយ។ លុះផ្តែផ្តាំរួចហើយគ្រុឌក៏ហោះផ្ចោះមហាសាគរហើយក៏បានចូលដល់មណ្ឌល ទីដើមជ្រៃរបស់ខ្លួន។

បន្ទាប់ពីបានប្រែកាយជាមាណពដ៏ ស្រស់ស្អាតរួចហើយក៏ប្រញាប់ចរចូលទៅរកព្រះមហាក្សត្រភ្លាម ... ព្រះអង្គព្រហ្មទត្តយល់ជាក់ជាមាណពមកដូច្នោះ ក៏ត្រាស់បង្គាប់អោយរៀបក្តារ អោយទ្រង់ក្រសាលបាស្កាជាមួយមាណព។

មាណពសង្ហារនៅលេងបាស្កាជាមួយស្តេច ព្រហ្មទត្តរហូតដល់ថ្ងៃរសៀលជ្រាលជ្រេរបន្តិចទើបថ្វាយបង្គំលាត្រលប់ ទៅទីស្ថានរបស់ខ្លួនវិញ។មាណពចេញផុតទៅព្រះអង្គព្រហ្មទត្តទ្រង់ក៏ យល់ឃើញគន្ធ័នមកដល់ដែរ ទ្រង់ត្រាស់សួរគន្ធ័នថា:

-ហែបង៏គន្ធ័ន បង៏ចរលើលាទៅរកកាកីនោះ តើបានដំណឹង៏យ៉ាង៏ណាដែរ?

គន្ធ័នស្តាប់ឮព្រះអង្គត្រាស់សួរដូច្នោះក៏ប្រញាប់ឆ្លើយថា:

-បពិតព្រះករុណាជាម្ចាស់ ទូលបង្គំជាខ្ញុំបានត្រេចរកគ្រប់ទិសទីមិនបានជួបបែជាទៅជួបឯមណ្ឌល សិម្ពលីឯណោះទៅវិញឃើញថា គ្រុឌវាបានពង្រ័ត់ក្សត្រីយកទៅរួមរស់ ជាមួយនឹង៏គ្នាមែន។ ចំនែកទូលបង្គំរង់ចាំមើលពេលគ្រុឌមិននៅល៏ បង្ហាញខ្លួនភ្លាម កាកីឃើញហើយដណ្ដឹង៏សួរទូលបង្គំ ប៉ុន្តែទូលបង្គំ ធ្វើជាស្រដីរឿង៏ផ្សេង៏ទៅវិញ ព្រោះចង់ដឹង៏ការពិតថាតើកាកីនៅបារម្ភពី សុខទុក្ខព្រះអង្គដែរឬទេ? ប៉ុន្តែគ្មានទេ កាកីបែជាមានកិរិយាមិន គប្បីគឺចូលជិតនិយាយដោយស្និទ្ធស្នាល និង៏ប្រើកលមាយាដាក់ទូលបង្គំ ទៅវិញ គ្មានទុក្ខបន្តិចសោះឡើយ ទូលបង្គំគិតក្នុង៏ចិត្តថាយើ:

"អ្នកនេះដល់ម្ទេះមិញតើ ឯម្ទេះថាបើ វិលមកបូរី។ ទំនង៏ជាល្អង៏ធូលី ព្រះបាទពុំគី- រម្យរួមស្នេហ៍ស្នង៏។

ត្បិតគ្រុឌពង្រ័ត់ទៅគ្រង៏រួមរសកន្ទង៏ជាពីអង្គហើយ។ ហើយច្បាប់ទំលាប់មុនឡើយ មហេសីត្រាណាត្រើយពុំដែលដូច្នេះ។

ទូលបង្គំគិតឃើញដូច្នេះហើយ ទើបហ៊ានលះលេងតទល់ និងនាងវិញដោយពុំបានទូលព្រះអង្គជាមុន។

ព្រះមហាក្សត្រព្រះបាទព្រហ្មទត្តទ្រង់សណ្ដាប់គន្ធ័ននិយាយដូច្នេះហើយទើបព្រះអង្គត្រាស់ទៅកាន់គន្ធ័នវិញថា:

-ហៃបងគន្ធ័ន បងកុំសង្ស័យគិតភ័យថ្វី ព្រោះថាអញនេះពុំយកទោសអ្វីពីបងឡើយ ចូរបងកុំបារម្ភខ្វាច ថ្វី។ សោកថ្វីមេស្រីចិត្តផ្ដាយនោះ បើវាដល់ម្ល៉េះអស់ហើយ តើនរណានឹង រាប់បានទៀត។ ហើយបើធ្វើខ្លាំងជាងនេះទៀតក៏អញមិនខឹងដែរអញនឹងពុំ យកគុណជាទោសឡើយ។ឥឡូវនេះចូរបងគិតរកឧបាយកលយ៉ាងណា ដើម្បីយកវាឲ្យ បានមកវិញគ្រាន់នឹងមើលមុខលេងកុំឲ្យវាពង្រត់គ្នាទៅនៅដោយបានសុខ សប្បាយតាមចិត្តវានោះ។ គន្ធ័នស្ដាប់អង្គមហាក្សត្រមានបន្ទូលរួច ទើបក្រាបបង្គំទូលថា:

-ទូលបង្គំគិតថា យើងត្រូវរង់ចាំ៧ទិវា សិន ទំរាំគ្រូឧមកទូលបង្គំនឹងយកពិនមកដេញ ហើយច្រៀងជាទំនុកទំនង ដែលទាក់ទងនិងពាក្យសំរើបសំរាលក្នុងតណ្ហាដែលទូលបង្គំបាននិត្យនៅនិងគ្នានោះ ទូលបង្គំជឿជាក់ថា បើគ្រូឧបានស្ដាប់នូវពាក្យអធិប្បាយ យ៉ាងនេះហើយប្រាកដជានឹងទ្រាំធ្មេចភ្នែកយកតទៅទៀតមិនរួចឡើយ មុខជា នឹងនាំយកកាកីមកវិញមិនខាន។ អង្គក្សត្រព្រហ្មទត្តទ្រង់សណ្ដាប់ពួក ន្ធ័ននិយាយដូច្នោះហើយ ទ្រង់មានព្រះទ័យសោមនស្សពេកក្រៃទ្រង់ើ មានបន្ទូលថា:

-ហៃគន្ធ័នបងអើយ បងនេះចេះត្រិះរិះត្រូវទំនង បើបានដូចប៉ងនោះយើងនឹងសប្បាយព្រះហរទ័យណាស់។

ទ្រង់មានបន្ទូលរួចហើយក៏យាងចូលក្រលាបន្ទំដោយព្រះទ័យសុខសប្បាយជាពន់ពេក។

## វគ្គទី ៩

លុះដល់គំរប់៧ថ្ងៃ ក៏បានឈានចូលមកយ៉ា ឆាប់រហ័សនៅសិម្ពលីគ្រុឌបក្សាបន្ទាប់ពីបានលាកាកីសំណាប់ចិត្តរួច ហើយក៏ស្ទុះហោះផ្ទេកផ្ទោះកាត់មហាសាគរធ្វើព្រងើយមិនបានខ្វល់ដឹងឮថា នឹងមានរឿងអ្វីកើតឡើងឡើយ។ មួយសន្ទុះក្រោយមកគ្រុឌក៏បានមកដល់មណ្ឌល ដើមជ្រៃហើយក៏ចូលទៅប្រែខ្លួនជាមាណពយ៉ាងឆាប់មួយរំពេច។ បន្ទាប់ពីរៀប ចួនប្រាណរួចហើយ មាណពក៏ប្រញាប់ធ្វើដំណើរទៅរាជវាំងភ្លាម។ ស្តេចព្រហ្មទត្តកាលបើឃើញមាណពហើយក៏ប្រញាប់រៀបចំក្តារដើម្បីឲ្យ ព្រះអង្គក្រសាលបាស្កាជាមួយ និងមាណពព្រះអង្គទ្រង់ទតមើលចំគន្ធ័ន គន្ធ័នយល់ការក៏ប្រញាប់ចាប់ពិនមកដេញលេងជាភ្លេងយ៉ាងពិរោះ រណ្តំ ហើយក៏ស្រែកច្រៀងថាៈ

ឱះឱព្រះពាយ រំភើយរំភាយ ផាត់ក្លិនគន្ធា
រសេរូបក្លិនស្រី កាកីស្ងួនភ្ជា បងចាំជាក់ជា
ក្លិនប្អូនមិញទេ។

ឱក្លិនកាកី មិនដូចអស់ស្រី នឹងស្រីអស់គេ
វែងតែអប់អស់ គន្ធរសរំលេប្ម៍ កាកីមាសមេ
ក្រអូបអង្គឯង។

ឱក្លិនកាកី ត្រកាលកលអ្វី ពិដោរល្ហើយល្វែង
ជិតដោយអង្គា កាលគ្រារៀមវែង ប្របលោមប្រលែង
ព្រលឹងប្អូនតន់។

ឱស្ថានសិម្ពលី ជាសុខឥតបី ឥតបើមានម-

និលទាល់តែបាត់ លះលាកតំបន់ ប្អូនអើយបងគន់

បងគិតដល់ស្រី។

ប្រាសប្រាំពីថ្ងៃ បាត់ក្លិនប្អូនថ្ងៃ ថ្ងៃនេះហេតុអ្វី

ពិដោរកក្លិនខ្លួន ប្អូនស្ងួនពិសី ដោយគេបេតី

តន់តូចពុំងារ។

ទើបជាប់ក្លិនមេ ក្លិនជិតដោយគេ ឈ្ងុយឈ្ងុបមហិមា

ឱម្រេះសមស្រី កាកីកល្យាណី នៅកំព្រាត្រមោចម្នាក់ឯង។

ចំនែកត្រុឌ កាលបើបានស្តាប់គន្ធ័ន ស្រែកច្រៀងក្តែងៗដោយឥតមានក្រែងរអែងចិត្ត សោះនោះ ក្នុងចិត្តនឹកក្រេវក្រោធយ៉ាងខ្លាំងគិតថា "អាដែងនេះច្រៀងជាទំនុកសរសើរពីកែវកន្និដ្ឋាហើយ..." គិតដូច្នោះហើយខំអត់សង្កត់ចិត្ត ធ្វើហាកមិនដឹង រឿងអ្វី ដើម្បីកុំអោយគេដឹងពិសេចក្តីពិត។

ឯគន្ធ័នសោត ដឹងដើមត្រុឌក្រោធ វេងរឹតចាប៉ី

ផ្សំស័ព្ទសួរសៀង ច្រូចច្រៀងស្រដី ថាឱស្រស់ស្រី

កែវកន្និដ្ឋា។

ម្ទេះសមនាងនឹក នាងនឹកសន្ទឹក សន្ទៃផ្សាយផ្សា

បើបានបងនៅ ថ្នមពៅឥឡូវជា សោះប្អូនវេរា

រំងាប់ចិត្តចៅ។

ស្តាយអើយមកប្រាស ព្រាត់វរមិត្រមាស ពុំបាននែបនៅ

ថ្នាក់ថ្នមផ្តេកផ្តិត ក្នុងចិត្តចង់ទៅ ទៀតតាមថ្នមពៅ

នៅស្ថានសិម្ពលី។

## វគ្គទី ៦

គ្រុឌបក្សា កាលបើបានឮគន្ធ័នច្រៀងរាលដាលដល់ស្ថានសិម្ពលីនោះក្នុងចិត្តវែង ខឹង ក្តួលក្តៅតានតឹងដូចកលព្រះអគ្គីឆាបឆេះពេញក្នុងឱរ៉ាស្មើតែ ទ្រាំមិនបាន ប៉ុន្តែខំសង្កត់ចិត្ត សួរទៅគន្ធ័នទាំងទើសទាល់ថាៈ

-នែអ្នកចំរៀង អ្នកច្រៀងរៀបរាប់ដឹងដល់សិម្ពលី អ្នកដឹងថាជាទីស្ថានរបស់គ្រុឌដែរឬទេ? យើងស្តាប់ហាក់ប្លែកណាស់ ព្រោះថាយើងមើលទៅអ្នកគឺជាមនុស្សដែលដើរដោយដីធម្មតាទេ ហេតុអ្វីក៏អ្នកបានដឹងពីទីស្ថានគ្រុឌដែលស្ថិតនៅទីទាល់ភ្នំ សត្តបរិភ័ណ្ឌឯណោះ ទៅវិញ។

អ្នកដឹងថាទីនោះមានព័ទ្ធទៅដោយជលធី គិរីឈ្មោះថាសត្តសីទន្តរមានទ្វីប៧ជាន់ មានទាំងសមុទ្រខ័ណ្ឌធំធេង ពេកក្រៃៗ ក្នុងសមុទ្រមានមច្ឆានិករកុម្ភា មានទាំងនាគកាច ពេកកន្ទង បើសិនមនុស្សសត្វធ្លាក់ចូលទៅក្នុងទឹកហើយគឺ មិនអាចមានជីវិតរស់បាន ឡើយ។ ចំនែកគ្រុឌគឺហោះផ្លោះផ្លោងរំលងអស់គិរីបុព្វតាមហាសមុទ្រនោះ ទើបបាន ទៅដល់មណ្ឌលទិព្វជាទីស្ថានសិម្ពលីនោះឯង។ យើងឆ្ងល់ថាហេតុម្តេចក៏អ្នកច្រៀងរៀបរាប់ ពីស្ថាននោះបាន អ្នកច្រៀងលេងទំនងដំនើរទីស្ថានដោយព្រេងនិទាន និងល្បើកអ្វីផ្សេងៗ ឬមួយក៏អ្នកចេះសិល្បីសាស្ត្រអាចហោះផ្លោះរំលងទៅបាន? ត្រង់ថាអ្នកបានទៅដល់នោះ យើងសែនឆ្ងល់ពេកកន្ទងបើអ្នកចេះរបៀនតើ បានរៀនពីគ្រូណាយើងសុំរៀនផងបានទេ? គន្ធ័នបានស្តាប់គ្រុឌចប់ហើយក៏សើចញញឹមហើយឆ្លើយប្រាប់គ្រុឌវិញ

-យើងនេះមិនបានហ៊ានផ្សងហោះផ្លោះផ្លោង ទៅនោះទេ កាលដែលយើងបានទៅនោះគឺយើងហ៊ានដោយសារគ្រុឌ យើងបានជ្រែករោមទៅឯស្ថានសិម្ពលី យើងបានជួបកែវកាកីគ្រុឌនៃបនិត្យស្នេហានាងនៅពេលរាត្រីលុះដល់ពេលថ្ងៃគ្រុឌតែងតែចេញ ទៅរកចំណីអាហារបេះផ្លែផ្កាផ្សេងៗដោយមិនដឹងថាយើងនេះនៅនៃបនិត្យ ស្នេហាកែវកាកីនាពេលថ្ងៃនៅទេ គិតទៅយើងនៅនឹកស្រណោះក្លិនខ្លួនស្ងួនពិដោរកែវកាកីណាស់ព្រោះធ្លាប់ថ្នាក់ថ្នមស្នេហាពេលគ្រុឌមិននៅធ្លាប់គេងកើយរួមខ្នើយតែមួយ ជាមួយគ្នារយៈពេល៧ថ្ងៃដែលយើងនៅជាមួយគ្នា។ ឱកែវកាកីស្ងួនមាសបងអើយពេលនេះសមព្រលឹងនៅស្ងាត់តែឯងហើយ មាសបងអើយបើសិនជាពុំមានគ្រុឌនោះ យើងនឹងរួមរស់ជាមួយគ្នាលុះអស់ជីព ជន តែបងគិតថាបងនឹងយកប្អូនមកឲ្យបានថ្វីត្បិតតែបងដើរដោយដីហើយធ្វើដំនើរហោះឆ្លងមហាសាគរដោយសារគ្រុឌក៏ពិតមែននោះ។ គន្ធ័នគិតតែច្រៀងថ្វាយព្រះមហាក្សត្រចំនែកគ្រុឌវិញស្តាប់កាន់តែ យូរកាន់តែមានអារម្មណ៍ហាក់គេយកកាំបិតមកចាក់ធ្មៀលក្នុងបេះដូងឲ្យ ឈឺផ្សារពេញអង្គប្រាណ គ្រុឌអោនមុខនិងពាក្យកាព្យទំនុករបស់គន្ធ័នក្នុងចិត្តនឹកខឹងផង ស្តាយផង ស្តាយក្លិនក្រអូប ស្តាយទាំងរូបកាយ ស្តាយចិត្តដែលខំស្រលាញ់អស់ពីឱរ៉ា ខឹងព្រោះខ្លួនខ្លៅ គេពុំកោតក្រែង ចាញ់ល្បិចគេ គេលបលួចទៅហើយគេយកច្រៀងថ្ងៃងកាលគេស្នេហាទៀត។ ឱខ្លួនអញអើយ អញនេះបំណាច់មានរិទ្ធិចេះប្រែក្រឡា ហោះផ្លោះរំលងជលសារ មិនគួរណាមកអាស្រូវកេរ្តិ៍ ដោយសារការប្រមាថប្រុសដូចគ្នា " លោកថាឲ្យមាន គំនិតគិតឲ្យាន កលកង់រាជរថ " ។ អញនេះបាត់សំលាញ់ក៏ព្រោះតែស្រី ស្រីស្រើបស្រាលពុំចេះស្កប់ ពុតស្រីដូច្នេះអញនិងចាំទុកអស់មួយជីវិត។ គ្រុឌគិតស្រេចហើយក៏ស្រដីទៅកាន់គន្ធ័នវិញថា:

-អើអ្នកប្រុសប្រាណ អ្នកពិតជាមានប្រាជ្ញារៀងវៃពិតណាស់ ផ្សំស្នូរសមស័ព្ទនិងពិណាពិរោះពេកក្រៃ ទុកដាក់សំដីជួបជូនឥតបី ទញ់ទាល់ទំនង។

និយាយចប់កាលណា គ្រុឌមាណពបានលាស្តេចព្រហ្មទត្តចរចេញទៅភ្នាមទៅដល់ដើមជ្រៃហើយ ក៏ប្រែក្រឡាជាគ្រុឌហើយហោះផ្លោះផ្លោងទៅដល់ស្ថានសិម្ពលីភ្លាម។ គ្រុឌ

បានសែកមន្តបើកទ្វារប្រាសាទចរចូលទៅយល់អង្គកាកីក្នុងចិត្ត ក្នុងចិត្តក្រោធពេកក្រៃ ដូចកលអគ្គីឆេះពេញឱរ៉ា ប៉ុន្តែគ្រុឌខំប្រឹងអត់សង្កត់ចិត្តខឹងទាំងប៉ុន្មានសិន គ្រុឌឡើងគង់លើអាសានៈ ហើយស្រដីសួរកាកីដោយស័ព្ទវាចារធម្មតាថាៈ

ហៃកាកីសួនមាសបង់ កាលដែលយើងយាត្រាចាកចេញពីនគរពារាណសីមកនៅស្ថានសិម្ពលីនេះ គិតទៅ ២២រាត្រីហើយ យល់ថាប្រាកដប្រកបដោយបានសុខសាន្តតែយើងចង់សួរថា តើមាននរណាអាចប្លែងបន្ទំខ្លួនចូលមកក្នុងប្រាសាទនៃបនិត្យជិតកាយ នាងដែរឬទេ?

កាកីស្តាប់ឮគ្រុឌសួរហើយក៏ឆ្លើយដោះសារថាៈ

-ព្រះអង្គអើយ តើនរណាឡើយនឹងទំលុះទ្វារនេះចូលបាន ខ្ញុំនៅតែម្នាក់ឯងសោះទេ មិនដែលយល់ដល់នរណាម្នាក់សោះឡើយ។

គ្រុឌស្តាប់កាកីហើយ ក្នុងចិត្តក្តួលក្តៅឆួលឆេះពេកកន្ទង់ ទឹកភ្នាញ់នឹងស្រដីឆ្លើយដោះសាររបស់កាកី គ្រុឌឆ្លើយតបវិញថាៈ

-ដើនេះនាងចេះធ្វើពើបានល្អណាស់ទេតើ ប៉ុន្តែការពិតនោះអញបានដឹងអស់ហើយ អញនេះខំស្រលាញ់អស់ពីចិត្តពីកាយមិនគិតពីរឿងបាបបុណ្យ មិនគិតពីកេរ្តិ៍ឈ្មោះត្រូវបាត់បង់ខំយកនាងមកគិតថានឹងនៃបនិត្យដូច កលជីវិតមូលអង្គតែមួយមិនដឹងអីចិត្តនាសាធារណ៍សោះនៅជាមួយគ្នា រាល់ថ្ងៃហើយនៅធ្វៀតមានសាហាយទៀត ឥលូវវាជិនណាយ វាត្រលប់ទៅស្ថានរបស់វាវិញហើយ ហើយនាងដឹងថាវាជានរណាទេ ? គឺជាគន្ធ័នកិលៀងរបស់ស្តេចព្រហ្មទត្តជាស្វាមីរបស់នាងនឹងហើយ។

## វគ្គទី ៧

កាកីស្តាប់ឮជាក់ក្នុងចិត្តភិតភ័យស្ទើរលោះព្រលឹងពេកណាស់តែខំប្រឹងធ្វើពើ ហើយនិយាយថាៈ

-នេះខ្ញុំចង់តែសើចទេ ហេតុម្តេចក៏ព្រះអង្គពោលដូច្នេះ? គឺអោយអាស្រូវពេកណាស់ ថាបើមាននរណាបានឃើញខ្ញុំនេះសាហាយ និងគន្ធ័ន សូមយកមកផ្ទាន់មកផ្ទឹមប្រទល់មុខ និងគ្នាមកហើយបើជាការពិតនោះ សូមកាត់សិរសារចុះសូមតែព្រះអង្គកុំថាខ្ញុំម្ចាស់នេះពុំត្រូវពុំត្រង់នោះ។ ព្រះអង្គគិតមើលថាស្ពានសិម្ពលីនេះស្ថិតនៅខ្ពស់ក្រៃពេកហួតជិត ជើងភ្នំព្រះសុមេរុឯណោះ តើមនុស្សឯណានឹងហ៊ានហោះផ្ទោះផ្ទោងឮសត្តសីទន្ទរបាន។ ចំនែកទ្វារទៀតក៏ចងដោយសាស្រ្តគមកុំថាឡើយមនុស្សទោះទេវតា ឥន្ទព្រហ្មឯណាក៏មិនអាចស្រាយបានដែរ។ គន្ធ័នក៏ដូច្នេះដែរ ទោះមានចិត្តប៉ុនប៉ងយ៉ាងណា ក៏មិនអាចហោះផ្ទោះផ្ទោងមកបានដែរ ហើយខ្ញុំម្ចាស់ទៀតនេះក៏ជាក្សត្រក្សាន្តពូជពង្សសណ្តានជាហង្សដែល ត្រូវជាគូនិងហង្សខ្ញុំម្ចាស់នេះមិនដែលភ្លេចខ្លួនបោះបង់ចិត្តចោរចបើកចង់ រហូតដល់ខ្លួនជាហង្សបែរជាទៅគប់គូរ និងក្អែកទៅវិញនោះដូចនេះសូមព្រះអង្គមេត្តាគិតរំលែកប្រណីព្រះទ័យប្រោសប្រាណដល់ខ្ញុំម្ចាស់ផងចុះព្រះអង្គ។ ខ្ញុំម្ចាស់ស្មោះស្ម័គ្ររួមស្ពាន និងព្រះអង្គហើយមិនទាន់បានប៉ុន្មានផង តើឲ្យខ្ញុំម្ចាស់នេះនឹងធ្វើម្តេចទៅកើត សូមព្រះអង្គគិតមើលផងចុះកុំជឿពាក្យញុះញង់របស់គេ នាំអោយធ្វល់វិលវល់កង្វល់ក្នុងប្រាណអីព្រះអង្គ។

គ្រុឌស្តាប់កាកីហើយ ក្នុងចិត្តរិតតែភ្ញាញ់ពេកកន្ទង ទើបវាចារទៅថា:

-អញនេះដឹងអស់ហើយ ស្រីពាលអប្រិយនេះ បើមិនដឹងពុតទេប្រាកដជាជឿនាងដោយកលដោយល្បិចក្បាច់ក្បូរដោះសារ របស់នាងហើយ តែពេលនេះនាងមិនបាច់បង្វេះបង្វែងសេចក្តីទេ គន្ធ័នវាបានដេញចាប៉ីច្រៀងថាវាបានមកដល់ទីនេះ ហើយបានរួមរស់ជាមួយនាងអស់រយៈពេល៧ថ្ងៃទៀតផង វាដេញចាប៉ីឌឺដងដោយពាក្យពាលចំពោះមុខធ្វើអោយអញខ្មាស់អស់មនុស្សា ស្ទើតែប្រែក្រលាជ្រែកមហាប្រឹថពីតែម្តងទេ។ យើងនេះគិតស្មានថានាងស្មោះស្មានថាជាហង្សតែងស្រង់ស្រះស្រីដឹងអី នាងជាស្រីស្រើបស្រាលមានប្រុសដោះដូរមិនចេះចប់ជាហង្សអប្រិយមក ផឹកទឹកថ្មុកល្អក់។ ចិត្តនាងប្រៀបដូចជាជលធី ដែលហូរគ្រប់ទិសទីមិនរើសព្រៃក នាងជាស្រីដែលល្អតែរូប ប៉ុន្តែចិត្តស្អុយក្រៃប្រៀបនឹងលាមកយើងនឹងនាំនាងត្រឡប់ទៅក្នុង រាត្រីនេះហើយ។

កាកីស្តាប់ព្ទដូច្នោះហើយ លើកដៃទាំងពីប្រណមហើយក្រាបទូលដោយអង្វរថាៈ

-សូមទានព្រះអង្គមេត្តាករុណា សូមទ្រង់មេត្តាឆ្ងៃងយល់ផង ពេលនេះម្ដេចឡើយក៏ព្រះអង្គជឿពាក្យគេថា ដោយកលប្រាជ្ញាដោយល្បិចសំដី នេះបើគេច្រៀងថាព្រះអង្គមានកែវភ្នែកព្រះឧទុរានោះ តើព្រះអង្គនឹងវះចិន្តាដោយពាក្យគេថាដែរឬអ្វី សូមព្រះអង្គសូមទ្រង់ព្រះចិន្តាផងចុះ។ បើព្រះអង្គស្ដាប់តែម្ខាង ហើយទ្រង់ក្រេវក្រោធយ៉ាងនេះ ខ្ញុំម្ចាស់នឹងសូមពិសោធថ្វាយ បើពិតដូចជាគេថានោះខ្ញុំម្ចាស់ហ៊ានបូជាជីវិតមិនស្ដាយឡើយនេះ ម្យ៉ាង។ ម្យ៉ាងទៀតបើព្រះអង្គនាំខ្ញុំម្ចាស់ត្រលប់ទៅនគរវិញខ្ញុំម្ចាស់ សុខចិត្តស្លាប់នៅទីនេះជាមួយព្រះអង្គប្រសើរជាងត្រលប់ទៅ។

គ្រុឌស្ដាប់ព្ទកាកីពោលពាក្យដោះសារធ្វើ ពើយ៉ាងនេះ រឹតតែខឹងទ្វេឡើមួយកំរិតទៀតគ្រុឌឡើងញ័រអស់អង្គប្រាណកន្ត្រាឡើងក្រហមទុំកែវភ្នែកស្ទើរស្រក់ឈាម ចំនែកក្នុងប្រាណស្ទើររលេះរលួយថ្លើមប្រមាត់សាច់សួតគ្មានសល់អ្វី ឡើយ។ គ្រុឌតបទៅវិញដោយសំដីមុតមាំថាៈ

-នែមេចោរច្រើនប្រួត អញឯងមិនឆ្គួត និងពាក្យនែមេមាយា។ បើអញរួមរក្សស្នេហា និងមេលុះអនាគត គេដៀលចំហុត។ ថាអញជាស្ដេចក្រុងគ្រុឌ ជាអ្នកពាលពុត អង្គុយជឿពាក្យមាយា។ វាផិតទុកចិត្តថាជា ធ្មេចភ្នែកស្នេហា ល្ងើលូងវង្វេងខ្លៅខ្លោះ។

ថាស្រេចគ្រុឌក៏ចាប់បីពរកាកីហោះ ផ្ទោះគីរីបុព្វតា មហាសាគរឆ្ពោះដល់ដែនដីពារាណសីភ្លាម។ បន្ទាប់មកក៏ដាក់កាកីនៅមុខទីព្រលានព្រហ្មទត្ត ហើយក៏ថាៈ

-នែហង កាលដែលនៅនិងអញមានប្រុសតែម្នាក់ នាងពុំស្កប់ពុំស្កល់ចិត្តល្បែង ឥលូវនេះហងប្រលែងនិងប្រុសឲ្យស្កប់ចុះ ទាំងថ្ងៃទាំងយប់កុំឲ្យស្ងប់ស្ងួតស្រាកស្រាន្ត។ ហើយតាំងពីពេលនេះរហូតដល់ទៅនិពាន្ត កុំឲ្យអញបានប្រសព្វដូច្នេះទៀតឡើយ។ ថាហើយគ្រុឌក៏

*ហោះផ្ទោះផ្ទោងធ្វើព្រងើយ សំដៅទីស្ថានសិម្ពលី ដោយទុកកាកីឲ្យនៅកណ្ដោចកណ្ដែង ម្នាក់ឯងមុខព្រះទីលានព្រះបាទព្រហ្ម ទត្ត។*

*ព្រឹកព្រាងព្រះសូរិយារះ បញ្ចេញរស្មីក្រហមច្រាលពេញផ្ទៃមេឃឯទិសបូព៌ មនុស្សម្នាទាំងឡាយក្រោកពីដំណេកចេញបំពេញការងាររៀងៗខ្លួន ចំនែកស្ដេចព្រហ្មទត្ត ព្រះអង្គទ្រង់តើនឡើងហើយ ទ្រង់ជំរះព្រះកាយលាបលាយគន្ធារសរួចទ្រង់អប់ព្រះពស្រ្តភូសា ព្រះទំរង់ ព្រះខ័ន រួចហើយទ្រង់ចរយាត្រាចេញមកក្រៅ ទ្រង់យល់អង្គកាកីអង្គុយនៅទីព្រះលានមួយអង្គឯង។ ទ្រង់យល់ឃើញដូច្នោះហើយ ក្នុងព្រះទ័យព្រះអង្គសែនក្រេវក្រោធពេកក្រៃអួលអាក់ក្នុងឱរ៉ាស្ទើរទ្រាំមិនបាន។ ព្រះអង្គខំអត់សង្កត់ព្រះចិន្តា ព្រោះចង់ជ្រាបដឹងពីល្បិចកិច្ចកលរបស់កាកី ទើបទ្រង់មានបន្ទូលចំអកចំអន់ទៅថាៈ*

*-ឱកាកីស្រស់ស្រីពន្ធកមាសបងអើយ ពេលដែលប្អូនបានទៅនៅនាស្ថានសួគ៌សោយសុខនោះ បងតែងតែទន្ទឹងមើលផ្លូវប្អូនសញ្ជប់សញ្ជឹងទាំងយប់ទាំងថ្ងៃស្ទើរផ្អុំ មិនលក់ ឥលូវនេះប្អូនបានមកព្រះលានហើយ ហេតុអ្វីក៏នៅធ្វើព្រងើយអង្គុយជ្រប់យ៉ាងនេះ អញ្ជើញប្អូនស្ងួនឡើងមកប្រាសាទសួស្ដី។ បងអរពេកពិតដែលប្អូនមកដល់នេះបងនឹកមិនភ្លេចទេកាលដែលបង ផ្ទុងផ្ដើមប្អូនពីមុនមកដល់ពេលនេះ បងតែងតំកើងប្អូនឲ្យខ្ពស់ជាងឯកឥតគូប្រៀបបានមានភិលៀងឆ្វេងស្ដាំ ចាំបំរើ មិនដឹងសោះថាប្អូនមានចិត្តគេចកែទៅស្នេហ៍ និងគ្រុឌប្រាសចាកពីប្រាសាទបរិពារទៅនៅដល់ស្ថានសិម្ពលី។ ប៉ុន្តែកាលដែលស្នេហ៍ស្និទ្ធ និងគ្រុឌបានតែប្រាំពីរាត្រីក៏ក្រឡាប់ក្រឡាស់ប្រែចិត្តទៅ ព័ទ្ធព័ន្ធ និងគន្ធ័នវិញ។ គិតទៅប្រុសមួយហើយទៅស្រវ៉ាចាប់ប្រុសមួយទៀត ថែមរហូតដល់ទៅបីនាក់ ពេលនេះតើស្កប់ឬនៅ? ឬមួយក៏ចង់ថែមដល់បួនប្រាំព្រួតទៀត? នាងធ្វើនេះមិនគួររាប់រកសោះ យើងខំលើកតំកើងនាងជាឆ្នើមលើនគរ តែនាងបែជាប្រព្រិត្តខ្លួនយ៉ាងនេះ លើជម្ពូទ្វីបទោះខំស្វែងរកពីតូចលុះមរណាក៏មិនបានដូចនាងដែរ គិតមើលតើឲ្យយើងយកនាងទុកម្ដេចបាន? កាកីបន្ទាប់ពីបានស្ដាប់បន្ទូលព្រះព្រហ្មទត្តរួចហើយ ក៏លុតជង្គង់លើកដៃសំពះហើយទូញទូលដោះប្រាណថាៈ*

-បពិត្រព្រះអង្គក្សត្រក្សាន្ត ខ្ញុំម្ចាស់មានចិត្តស្រលាញ់ព្រះអង្គឥតមានធ្វេសធ្វេសអាករឡើយ សូមព្រះអង្គទ្រង់ព្រះចិន្តាផងចុះ... កាលដែលកើតព្យុះខ្យល់ងងិតសូនសុងនោះ ក៏លេចគ្រុឌ តិរិច្ឆានចូលក្នុងទីស្ថានរាជដំណាក់របស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ខំប្រឹងស្រែកហៅព្រះអង្គ តែមិនឃើញព្រះអង្គទៅឡើយ ពេលនោះគ្រុឌក៏ចាប់ ពរបីខ្ញុំម្ចាស់ហោះចេញទៅ។

## វគ្គទី ៨

ខ្ញុំម្ចាស់ពុំគិត ពុំចូលចាប់ចិត្ត ស្នេហ៍និងគ្រុឌា
ដែក្តិចខ្វារខ្វាំ ដេរខាំដៀលថា ឲ្យលែងចោលនា
កណ្តាលនភី។
ឲ្យធ្លាក់ចូលក្នុង សមុទ្រលិចលង់ ក្សិណក្ស័យជីវី
ត្បិតឃ្លាតបង់បោះ នឹងអង្គចក្រី គ្រុឌជាបក្សី
ពុំលែងពុំស្តាប់។

គ្រុឌពុំស្តាប់ខ្ញុំម្ចាស់ឡើយ គិតតែខំ ហោះផ្ទោះផ្ទោងរហូតដល់ទីស្ថានរបស់គ្រុឌខ្ញុំម្ចាស់សោយសោកស្មើ ស្ទាប់ខ្លួនទឹកភ្នែកស្រក់ហូរមិនដាច់បីដូចលោហិត ខ្ញុំម្ចាស់ពុំមាន ចិត្តប្រែពីព្រះអង្គបែស្រលាញ់គ្រុឌឡើយ។ ប៉ុន្តែដោយរិទ្ធិអំនាច របស់គ្រុឌ ឯខ្ញុំម្ចាស់ជាស្រី និងមានកំលាំងអ្វីទៅតបតមានតែកើតទុកពុំស្រាកស្រាន្ត គិតថាបើគ្រុឌមកបៀតបៀនខ្លួនប្រាណនោះខ្ញុំម្ចាស់នឹងស៊ូក្ស័យហើយ ព្រោះតែចិត្តគិតតែព្រះអង្គមួយគត់ ព្រោះគិតថាក្រែងថ្ងៃណាមួយ ខ្ញុំម្ចាស់នឹងបានត្រឡប់មកជួបព្រះអង្គវិញ តែបើមិនបានមកទេនោះ ខ្ញុំម្ចាស់សូមក្ស័យទៅវិញប្រសើជាង។ ប៉ុន្តែពេលនេះខ្ញុំម្ចាស់ និយាយតើមាននរណានឹងជឿពីចិត្តស្មោះរបស់ខ្ញុំម្ចាស់ចំពោះ ព្រះអង្គ ជារៀងរាល់ថ្ងៃខ្ញុំម្ចាស់តែងអង្វរករគ្រុឌសូមអោយគ្រុឌជិនណាយ និងជូនខ្ញុំម្ចាស់មកព្រះអង្គវិញ។ ជាសំណាងល្អ បាន៧ថ្ងៃគន្ធ័ នវាងវៃក៏បានទៅ

ដល់ស្ថានសិម្ពលី ប្រាប់ថាព្រះអង្គកើតទុក្ខពុំ ស្បើយ ខ្ញុំម្ចាស់ដឹងហើយក៏ស្លុតចិត្តស្ទើរក្ស័យ ញាប់ញ័រក្នុងចិត្ត ផងឹតមុខដួលសន្ធប់បាត់ស្មារតី ដោយមិនដឹងថាគន្ធ័នបានធ្វើអ្វី ចំពោះខ្ញុំម្ចាស់នោះទេ ខ្ញុំម្ចាស់ក៏មិនបានដឹងសោះថាចិត្តគាត់ ដូច្នោះដែរ នេះខ្ញុំម្ចាស់ទូលព្រះអង្គសុទ្ធតែជាពាក្យពិតពុំបានមុសា អ្វីឡើយ។ អង្គក្សត្រព្រះបាទព្រហ្មទត្តទ្រង់សណ្ដាប់នូវពាក្យទូញទូលចញ្ចូលព្រះចិន្ដារបស់កាកីហើយទ្រង់ក្ដៅក្នុងឱរ៉ាប្រៀបដូច ភ្លើងឆេះព្រះកាយទ្រង់មានព្រះរាជឱង្ការដោយអាជ្ញាដែលមានព្រះ សូរខ្លាំងៗថាៈ

អញជាចមក្សត្រ ឥសូរពាស្ត្ររដ្ឋ គ្រប់គ្រងនគរ
ឱរត់អ្វីខ្មោចស្រី ចំណីរាគា ស្រីអញមានជា
រាប់រយសែនសល់។

រីខ្លួនមេមួយ កុំបីមេព្រួយ ដោះសារវិលវល់
នឹងយកមេទុក ជូន់ស្រុកអំពល់ នឹងឲ្យដឹងដល់
ប្រទេសនានា។

បើគេដឹងរឿង ដឹងរ៉ាវក្បួនក្បឿង គេនឹងនិន្ទា
រីមាយាមេ សមតែដាក់នា ពោងពាយឲ្យវ៉ា
អណ្ដែតទឹកទៅ។

នេះហើយទើបសមគំនិតស្រី ចិត្តចើក។ ព្រះអង្គព្រហ្មទត្តមានបន្ទូលរួចហើយក៏ត្រាស់បង្គាប់ទៅអា មាត្រថា "ឲ្យយកកាកីទៅដាក់ពោងពាយទៅ"បានដូចព្រះចិន្ដាអាមាត្រក៏ ម្នីម្នាទៅនាំកាកីចេញទៅកំពង់ទឹកភ្លាម ទៅដល់ហើយក៏ដាក់កាកីបណ្ដែត ក្នុងពោងពាយ ហើយប្រានចេញទៅយ៉ាងលឿនស្ទៅផុតពីកំពង់ទឹកសមដូច ព្រះរាជអាជ្ញារួចស្រេចហើយក៏នាំគ្នា

ត្រលប់ទៅទូលព្រះមហាក្សត្រព្រហ្ម ទត្តរាជាតាមដំនើររឿងក្សត្រទ្រង់សណ្តាប់ហើយមានព្រះរាជ ឱង្ការ ថាៈ " នេះហើយទើបសមមុខវា"

## វគ្គទី ៩

ឈប់ស្ទេះត្រឹមនេះរឿស្តេចព្រហ្មទ ត្ត យើងបែរមកមើលកាកីត្រូវបណ្តែតពោងពាយត្រូវខ្យល់បក់រសាត់ផាត់ កណ្តោចកណ្តែងតែឯកឯងសែនសង្វេកចិត្តខ្សឹកខ្សួលអួលអាក់នាងសោយសោក ទឹកភ្នែកហូរឥតឈប់បែរមកក្រោយមើលស្រុកនឹកស្តាយសព្វសារពើ ស្តាយកេរ្តិ៍ឈ្មោះដែលធ្លាប់ជាធំលើសអស់ស្នំទាំងឡាយ ធ្លាប់រស់នៅសុខ សប្បាយមានខ្ញុំកំដរឆ្វេងស្តាំ ស្តាយតូរតន្ត្រី ភ្លេងមហោរីធ្លាប់រេ រាំកំសាន្តកាយ ស្តាយទែនសយនាជាកន្លែងសុខសម្រាន្តស្តាយស្រះស្រង់ ឧទ្យានតែងក្រសាលឥតឯឃ្លាត ស្តាយបុណ្យដែលបានទៅនៅប្រាង្គប្រាសាទ ដ៏ល្អប្រណីតមិនគួរកម្មអ្វី ប្រាស់ព្រាត់មកនៅលើពោងពាងតែឯកឯងទៅវិញៗ កាកីអង្គុយមើលទៅមុខទៅក្រោយ ឆ្វេងស្តាំគឺសុទ្ធតែទឹកទាំងអស់ គ្មានកោះគ្មានត្រើយគឺមានតែទឹក និងមេឃតែប៉ុណ្ណោះ ទឹករលកបោកផ្ទប់បែកខ្ចាយ មច្ឆាតូចធំហែលមកបង្អើយ ហាមាត់សឹងត្របាត់បរិភោគ នាងភិតភ័យជាពន្ទពេកទួញយំរៀបរាប់ថាៈ

-ឱពីថ្ងៃនេះតទៅ ខ្ញុំប្រាសព្រាត់ អស់ហើយទីលំនៅធ្លាប់សុខសប្បាយស្រីស្នំខ្ញុំកំដរទាំងឡាយព្រាត់ទាំង ព្រះរាមដ៏ឧត្តមទៀតផង តើពេលនេះបាននរណាជាទីពំនាក់ៗ

នាងយំរៀបរាប់មិនឈប់ឱ៉ាស្ទើរប្រេះ ធ្លាយនាងប្រះខ្លួននទៀលក៏បាត់ស្មារតីទៅៗ លុះភ្ញាក់ស្មារតីឡើងវិញ នាងនឹកឃើញកាលព្រះអង្គព្រហ្មទត្តស្វែងរកឥសីដើម្បីទៅនមស្សការនាង គិតថាៈ

-ឱពេលនោះអញយកកំណើតក្នុងផ្កា កណិកា ដែលមានរសកលិនក្រអូបក្រអែបលើសផ្កាទាំងពួង តាបសឥសីមានព្រះគុណ បានយាត្រាទៅយកអញចេញពីក្នុងផ្កា ហើយសន្មត់នាមតាមឈ្មោះផ្កា ថា"កាកីៗ កាលណោះតាបសបានប្រទានខ្ញុំឲ្យទៅព្រះអង្គ ហើយទ្រង់ក៏

នាំ ខ្ញុំទៅដល់ទីស្ថានមណ្ឌល ហើយក៏បានអភិសេកខ្ញុំជាមហេសី ឱម្តេច ពេលនេះព្រះអង្គពុំគិត ពុំអាណិតទឹកប្រណីអាសូរខ្ញុំជាស្រី ត្បិត ឥសីបានផ្តាំថា:

ទោះទោសខ្ញុំធ្ងន់ធ្ងរ គួរព្រះបងជូនប្អូនផង

ទៅឯឥសីលា ឬក្សត្រានឹងឥឡូវក្រៀមយ។

គួរស្តេចនឹងសម្លាប់ ឲ្យខ្ញុំស្លាប់នៅក្រុងក្រៃ

ម្ចាស់អើយប្អូនមហាភ័យ ភិតរីតស្ងាំងស្លុតពន់ពេក។

ឱយប់យូរទៅហើយ ខ្ញុំសំលឹងទៅមេឃឃើញ តារារះពាយព្រោងព្រាតភ្លឺត្រចះត្រចង់ ពពករសាត់កាត់ផ្ទៃមេឃស្រឡះ មើលចុះព្រះច័ន្ទរះភ្លឺថ្លាប្រៀបបាននឹងព្រះអង្គដែលមានតារារះ ព័ទ្ធជុំវិញប្រៀបដូចជាស្នំ ចាំគាល់នៅជាប្រក្រតី

ឱប្អូនធ្លាប់រែងនៅ នឹងព្រះចៅជាមហេសី

គឺកម្មកាយប្អូនស្រី នានាំនែបនឹងគ្រូឱ។

កម្មម្តេចនាំប្រសព្វ នឹងគន្ធព្វទៀតពីរគ្រា

ទាំងនេះហេតុវេរា នឹងនិរាសរៀមទៀតទៅ។

ឱពាក្យចាស់បុរាណលោកតែពោលថា "អ្នកណា លូកភ្លើង អ្នកនោះនឹងក្តៅ" "អ្នកណាសាងកម្ម កម្មនោះនឹងតាមសងវិញមិន ខាន" ដូចរូបខ្ញុំនាពេលនេះគឺកម្មតាមដោយដានប្រៀបបាននឹង ស្រមោល អន្ទោលតាមប្រាណកម្មនេះគឺកម្មក្រាស់ក្រៃកន្ទង់នឹងរកអ្វីមកប្រៀបពុំបាននេះគឺកម្មពីព្រេងនាយនាំឲ្យវង្វេងចិត្តគិតអ្វីមិន យល់ឡើយ។ ស្រណោះធ្លាប់ផ្ទឹមព្រះចៅចមចក្រី ធ្លាប់មហេសីដែល ព្រះអង្គនែបនិត្យជិតប្រក្រតីមិនដែលឃ្លាត។ ស្រណោះកាលមួយនៅស្ថាន សិម្ពលី សែនសប្បាយជាពន់ពេកមិនគួរគន្ធ័នទៅលែបខាយ

ឲ្យអន្តរាយដល់ រូបកាយយ៉ាងនេះទេ។ ឥលូវនេះខ្ញុំមករងទុក្ខតែម្នាក់ឯងកណ្តាល គង្គា ពីថ្ងៃនេះតទៅមានតែសេចក្តីស្លាប់តែប៉ុណ្ណោះនេះបើស្លាប់នៅលើ គោកគ្រាន់បានតាបសឥសីព្យាបាលឲ្យរួចជីវិត តែពេលនេះមកស្លាប់ក្នុង ទឹកសមជាចំណីត្រីជាក់ជាមិនខាន។ ឱខ្លួនខ្ញុំអើយកើតមកកំព្រា ម្នាក់ឯងកណ្តាលផ្កា តើនឹងបាននរណាមកជួយស្រោចពីគង្គាទៅលាក់បំពួនបានសង្ឃឹមព្រះសិទ្ធាលោកនៅឯព្រៃស្មសាន តើនឹបាននរណានាំពត៌មាន ទៅប្រាប់គាត់ពេលនេះខ្ញុំមានតែសេចក្តីទុក្ខទួញយំតែប៉ុណ្ណោះមើលចុះ ណាខ្លាចត្រីធំៗហែលមកក្បែរផង ណាខ្លាចរលកបោកបក់ម្តងសឹងប៉ុនភ្នំ។

ឱគួរឲ្យអាណិតកែវកាកីណាស់ កើតទុកកណ្តោចកណ្តែងសោកសង្រេងលើពោងពាយដែលអណ្តែតលោតប៉ប្រឹមប៉ប្រុងកណ្តាល ជលសារតាមកំលាំងខ្យល់បក់ លុះគម្រប់៧ទិវាពោងពាយកំសត់ក៏ត្រូវរលកបោកបែកខ្ចាត់ខ្ចាយពីគ្នា នាំយករូបកាកីឲ្យលិចលង់ក្ស័យជនជីវីក្នុង មហាសាគរដ៏សែនជ្រៅនោះទៅ។

រឿងកាកីសន្មត់ថាចប់ត្រឹម ប៉ុណ្ណោះ រឿងនេះព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះបរមកោដ្ឋ) ព្រះអង្គបានរៀបចំចងក្រងរឿងនេះឡើងទុកជាគំរូដល់យុវត្តីក៏ដូចជាស្ត្រីខ្មែរគ្រប់រូបកុំឲ្យយកតំរាប់តាមកែវកាកី គឺថាទីបំផុតបានត្រឹមអន្តរាយខ្លួនឯងតែប៉ុណ្ណោះ។

ដកស្រង់ចេញពី GOLD TIPS